Article
September 2021

# ការអភិវឌ្ឍទីក្រុងឆ្លាត៖ ករណីកម្ពុជា និងអាស៊ាន

កំណើនប្រជាជនលើពិភពលោកបានកើនឡើងគួរឱ្យកត់សម្គាល់នារយៈកាលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ។ បច្ចុប្បន្ន ប្រជាជនពិភពលោកច្រើនជាងពាក់កណ្ដាល (ប្រមាណ ៥៦%) កំពុងរស់នៅតាមបណ្ដាទីក្រុងនានា ហើយចំនួននេះនឹងបន្តកើនឡើងជាលំដាប់ រហូតដល់ប្រមាណ ៦៨% នៅត្រឹមឆ្នាំ ២០៥០ ជាមួយសន្ទុះនៃនគរូបនីយកម្មដែលកើនឡើងឥតឈប់ឈរ នេះបើយោងតាមរបាយការណ៍របស់**អង្គការសហប្រជាជាតិ**។ ជាក់ស្ដែង ប្រជាជនភាគច្រើនធ្វើចំណាកស្រុកទៅកាន់ទីក្រុងដោយសង្ឃឹមថានឹងទទួលបានជីវភាពកាន់តែល្អប្រសើរ។ ការណ៍នេះបានបង្កជាសម្ពាធលើធនធានហេដ្ឋារចនាសម្ព័ន្ធ បរិស្ថាន និរន្តរភាពសង្គម និងសេដ្ឋកិច្ចនៅក្នុងទីក្រុង ខណៈដែលតម្រូវការមានការកើនឡើងជាបន្តបន្ទាប់។ ក្នុងន័យនេះ ចាំបាច់ទាមទារឱ្យមានការគិតគូររកដំណោះស្រាយសម្រាប់ការអភិវឌ្ឍទីក្រុងប្រកបដោយនិរន្តរភាព និងភាពប្រកួតប្រជែង ដោយក្នុងនោះការកសាងទីក្រុងឆ្លាតត្រូវបានមើលឃើញថាជាយុទ្ធសាស្ត្រដ៏ល្អមួយដែលអាចជួយដោះស្រាយបញ្ហាកំណើនប្រជាសាស្ត្រ និងនគរូបនីយកម្ម ដោយហេតុថាបច្ចេកវិទ្យាក្នុងទីក្រុងឆ្លាតអាចជួយកាត់បន្ថយការប្រើប្រាស់ថាមពល ការបញ្ចេញឧស្ម័នពុល និងជួយដល់ការគ្រប់គ្រងសំណល់ក្នុងទីក្រុងបានកាន់តែប្រសើរ។

គោលគំនិតរបស់ **«ទីក្រុងឆ្លាត»** តាមប្រទេសនីមួយៗនៅលើពិភពលោក ត្រូវបានឱ្យនិយមន័យ និងមានការបកស្រាយផ្សេងៗគ្នាស្របតាមបរិបទប្រទេស។ ជាទូទៅ **«ទីក្រុងឆ្លាត» សំដៅដល់ទីក្រុងដែលប្រើប្រាស់បច្ចេកវិទ្យាជាជំនួយសម្រាប់ការដោះស្រាយបញ្ហានានាដែលកើតមាននៅក្នុងទីក្រុង សំដៅពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការ លើកកម្ពស់គុណភាពសេវាសាធារណៈ ធ្វើឱ្យគុណភាពជីវិត និងសុខុមាលភាពប្រជាពលរដ្ឋកាន់តែល្អប្រសើរ និងធានានិរន្តរភាពនៃការអភិវឌ្ឍ។ «ទីក្រុងឆ្លាត»** មានសមត្ថភាពក្នុងការគ្រប់គ្រងហានិភ័យសង្គមនានា ដោយប្រើប្រាស់បច្ចេកវិទ្យា និងប្រព័ន្ធវៃឆ្លាត។ បច្ចេកវិទ្យាក្នុងទីក្រុងឆ្លាតមានដូចជា បញ្ញាសិប្បនិម្មិត (AI), បច្ចេកវិទ្យាប្លុកឆេន (Blockchain Technology), ទិន្នន័យធំ (Big Data), បច្ចេកវិទ្យាថាមពលកកើតឡើងវិញ (Renewable Energy), ប្រព័ន្ធអ៊ីនធឺណិតនៃវត្ថុ (IoT) និងប្រព័ន្ធព័ត៌មានភូមិសាស្ត្រជាដើម។

ទស្សនទានក្នុងការកសាងទីក្រុងឆ្លាតដំបូងគេបង្អស់នៅលើពិភពលោកត្រូវបានអនុវត្តនៅទីក្រុងសេអ៊ូលរដ្ឋធានីនៃប្រទេសកូរ៉េខាងត្បូង កាលពីឆ្នាំ២០១៤។ ដោយឡែក បច្ចុប្បន្ននេះ សិង្ហបុរីត្រូវបានគេចាត់ទុកថាជាទីក្រុងឆ្លាតជាងគេនៅលើពិភពលោក។ កត្តាចំបងដែលធ្វើឱ្យទីក្រុងមួយក្លាយជាទីក្រុងឆ្លាត គឺសមត្ថភាពក្នុងការធានាសុវត្ថិភាព និងនិរន្តរភាពដោយផ្ដោតលើសុខុមាលភាពរបស់

ប្រជាជន។ ទីក្រុងឆ្លាតផ្តោតលើភាពងាយស្រួលក្នុងការធ្វើដំណើរ ការធ្វើឱ្យប្រសើរឡើងនូវវិស័យសុខាភិបាល ការគ្រប់គ្រងសំណល់ប្រកបដោយប្រសិទ្ធភាព ក៏ដូចជាការកែលម្អគុណភាពសង្គម និងសេដ្ឋកិច្ច ដោយប្រើប្រាស់នូវបច្ចេកវិទ្យាឆ្លាត។ ខាងក្រោមនេះ យើងនឹងលើកយកករណីសិក្សាទីក្រុងឆ្លាតនៅក្នុងតំបន់អាស៊ាន ដោយផ្តោតលើប្រទេសសិង្ហបុរីដែលជាគំរូមួយក្នុងការកសាងទីក្រុងឆ្លាត។ ជាមួយគ្នានេះផងដែរ ករណីសិក្សារបស់ប្រទេសកម្ពុជាក៏នឹងត្រូវលើកយកមកបង្ហាញ ដោយផ្តោតលើគោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលក្នុងកិច្ចខិតខំប្រឹងប្រែងកសាងទីក្រុងឆ្លាត។

## I. ការកសាងទីក្រុងឆ្លាតនៅក្នុងតំបន់អាស៊ាន

ទីក្រុង ត្រូវបានចាត់ទុកជាមូលដ្ឋានសំខាន់មួយសម្រាប់ការអភិវឌ្ឍរបស់អាស៊ាន។ បច្ចុប្បន្ន មានប្រជាជនប្រមាណ ៣២០លាននាក់ កំពុងរស់នៅតាមបណ្តាទីក្រុងនានានៅក្នុងតំបន់អាស៊ាន ហើយតាមការប៉ាន់ស្មាន ចំនួននេះនឹងអាចកើនដល់ប្រមាណ **៥២៥លាននាក់** នៅត្រឹមឆ្នាំ២០៥០។ កំណើនប្រជាជនមករស់នៅទីក្រុងបានចោទជាបញ្ហាដូចជា ការកកស្ទះ, ការប៉ះពាល់ដល់គុណភាពទឹក និងខ្យល់, ការកើនឡើងនៃវិសមភាព, ព្រមទាំងបញ្ហាសន្តិសុខ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋផងដែរ។ ដោយមើលឃើញពីបញ្ហាប្រឈមទាំងនេះ ប្រមុខរដ្ឋនៃបណ្តាប្រទេសដែលជាសមាជិកអាស៊ានបានសម្រេចបង្កើតនូវ **«បណ្តាញទីក្រុងឆ្លាតអាស៊ាន» (ASEAN Smart Cities Network - ASCN)** នាឱកាស**កិច្ចប្រជុំកំពូលអាស៊ានលើកទី៣២** ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៨។ ប្រទេសជាសមាជិកអាស៊ានទាំង១០ នឹងធ្វើការរួមគ្នា ឆ្ពោះទៅរកគោលដៅរួមក្នុងការអភិវឌ្ឍទីក្រុងឆ្លាត ដោយប្រើប្រាស់នូវបច្ចេកវិទ្យា ដើម្បីពង្រឹងសកម្មភាពសេដ្ឋកិច្ច សង្គម និងបរិស្ថាន ព្រមទាំងឆ្លើយតបទៅនឹងបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងអនាគត។ សមាជិកអាស៊ានបានកំណត់យកទីក្រុង ២៦ ជាគោលដៅសម្រាប់ការកសាងទីក្រុងឆ្លាត ក្នុងនោះមានទីក្រុងរបស់ប្រទេសកម្ពុជាចំនួន ៣ រួមមាន ទីក្រុងភ្នំពេញ, ទីក្រុងសៀមរាប និងទីក្រុងបាត់ដំបង។

នៅក្នុងយុទ្ធសាស្ត្រនៃការកសាងទីក្រុងឆ្លាតរបស់អាស៊ាន ទីក្រុងត្រូវសម្រេចឱ្យបាននូវតុល្យភាពរវាងគោលដៅសំខាន់ៗចំនួន ៣ រួមមាន៖

### ទី១. សេដ្ឋកិច្ចដែលមានភាពប្រកួតប្រជែង៖

ការកសាងទីក្រុងឆ្លាតរបស់អាស៊ានផ្តោតលើការសម្រេចឱ្យបាននូវសេដ្ឋកិច្ចដែលមានភាពប្រកួតប្រជែង ដើម្បីផ្តល់ឱកាសឱ្យប្រជាពលរដ្ឋគ្រប់រូបអាចទទួលបានការលើកកម្ពស់គុណភាពជីវិត ដោយមិនទុកនរណាម្នាក់នៅក្រៅការអភិវឌ្ឍ។ លើសពីនេះទៀត សេដ្ឋកិច្ចដែលមានភាពប្រកួតប្រជែងក៏ចូលរួមលើកទឹកចិត្តដល់ការបង្កើតធុរកិច្ចថ្មី តាមរយៈការផ្តល់ការគាំទ្រសហគ្រិនភាព ពិសេសសម្រាប់យុវជន ព្រមទាំងជួយដល់ការបង្កើនប្រភពចំណូលរបស់ប្រជាពលរដ្ឋ បង្កើតឱកាសការងារ និងការវិនិយោគ។

### ទី២. បរិស្ថានប្រកបដោយនិរន្តរភាព៖

ការកសាងទីក្រុងឆ្លាតរបស់អាស៊ានផ្តោតលើការធានាឱ្យបាននូវការគ្រប់គ្រងបរិស្ថាន ប្រកបដោយនិរន្តរភាព សំដៅពង្រឹងប្រព័ន្ធអេកូឡូស៊ី ដែលគ្របដណ្តប់លើធនធានធម្មជាតិ និងបញ្ចៀសនូវគ្រោះមហន្តរាយដែលអាចកើតឡើង ព្រមទាំងកាត់បន្ថយផលប៉ះពាល់នៃបញ្ហាបម្រែបម្រួលអាកាសធាតុ។ បញ្ហាបរិស្ថានក៏ជាកត្តាសំខាន់សម្រាប់ធានាដល់ការរីកចម្រើននៅក្នុងតំបន់អាស៊ានផងដែរ។ ក្នុងន័យនេះ ទីក្រុងដែលជាសមាជិកក្នុងបណ្តាញទីក្រុងឆ្លាតអាស៊ាន ត្រូវរួមគ្នាលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាបៃតង និងថាមពលបៃតង (Green Technology and Energy) ព្រមទាំងលើកកម្ពស់ការផលិត និងការប្រើប្រាស់ប្រកបដោយនិរន្តរភាព។

### ទី៣. គុណភាពជីវិតកាន់តែប្រសើរ៖

ការកសាងទីក្រុងឆ្លាតរបស់អាស៊ានក៏បានផ្តោតលើការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋទាំងលើផ្នែកសង្គម កាយសម្បទា និងសុខុមាលភាពផ្លូវចិត្ត។ ទីក្រុងឆ្លាតគួរលើកកម្ពស់ការទទួលបានទំនិញ និងសេវាកម្មដែលមានគុណភាព និងប្រកបដោយសមធម៌ ព្រមទាំងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសង្គម រួមមាន សេវាអប់រំ សេវាថែទាំសុខភាព លំនៅដ្ឋាន សន្តិសុខ សុវត្ថិភាព ការអភិរក្សវប្បធម៌ និងធនធាននានាដែលអាចជួយឱ្យជីវិតពលរដ្ឋកាន់តែប្រសើរ។ ការលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋគឺជាកត្តាគន្លឹះក្នុងការធានាបាននូវសង្គមមួយ ប្រកបដោយសមធម៌ បរិយាបន្ន និងគង់វង្ស។



## II. ករណីសិក្សា៖ សិង្ហបុរីជាទីក្រុងឆ្លាតបំផុតនៅលើពិភពលោក

សិង្ហបុរីជាប្រទេសមួយដែលមានដង់ស៊ីតេប្រជាជនខ្ពស់ ប្រមាណ ៧៨០០នាក់/គីឡូម៉ែត្រការ៉េ ដោយមានប្រជាជនរស់នៅច្រើនកុះករនៅក្នុងតំបន់ទីក្រុង ជាមួយកំណើនសេដ្ឋកិច្ច នគរូបនីយកម្ម និងការកើនឡើងខ្លាំងនៃការធ្វើអន្តោប្រវេសន៍ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដែលបានបង្កជាសម្ពាធដល់ហេដ្ឋារចនាសម្ព័ន្ធ និងធនធាន ព្រមទាំងធ្វើឱ្យតម្លៃផ្ទះឡើងថ្លៃជាខ្លាំង។ មិនតែប៉ុណ្ណោះ សិង្ហបុរីក៏ជួបប្រទះបញ្ហាកំណើនមនុស្សចាស់ និងការថយចុះនៃអត្រាកំណើត។ បច្ចុប្បន្ន នៅសិង្ហបុរី ចំនួនមនុស្សចាស់ដែលមានអាយុលើសពី៦៥ឆ្នាំ មានចំនួនជិត ១លាននាក់ ហើយចំនួននេះត្រូវបានគេរំពឹងថានឹងកើនឡើង ៣ដង នៅត្រឹមឆ្នាំ ២០៥០ ខាងមុខ។ ក្នុងន័យនេះ រដ្ឋាភិបាលសិង្ហបុរីបានបង្កើតនូវគំនិតផ្តួចផ្តើមថ្នាក់ជាតិក្នុងការកសាង **«ប្រជាជាតិវៃឆ្លាត» (Smart Nation)** កាលពីឆ្នាំ២០១៤។ គំនិតផ្តួចផ្តើមនេះ ផ្តោតលើការប្រើប្រាស់បច្ចេកវិទ្យាដើម្បីលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋ និងដោះស្រាយបញ្ហាដែលសិង្ហបុរីកំពុងជួបប្រទះ។ ជាលទ្ធផល នៅឆ្នាំ២០២០ សិង្ហបុរីបានជាប់ចំណាត់ថ្នាក់ជា**ទីក្រុងឆ្លាតជាងគេនៅលើពិភពលោក** នេះបើយោងតាមរបាយការណ៍រួមគ្នាប្រចាំឆ្នាំរបស់ Institute for Management Development និង Singapore University for Technology and Design (SUTD)។ ការដាក់ចំណាត់ថ្នាក់នេះគឺផ្អែកលើទិន្នន័យសេដ្ឋកិច្ច និងបច្ចេកវិទ្យា រួមជាមួយការយល់ឃើញរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងទីក្រុងនោះផ្ទាល់។ ខាងក្រោមនេះជាបច្ចេកវិទ្យា និងការអនុវត្តសំខាន់ៗដែលសិង្ហបុរីប្រើប្រាស់ក្នុងគម្រោងទីក្រុងឆ្លាត៖

### ១. ការធ្វើបម្លាស់ទីឆ្លាត (Smart Mobility)

សិង្ហបុរីបានប្រើនូវប្រព័ន្ធដឹកជញ្ជូនឆ្លាត ដើម្បីសម្រួលចរាចរណ៍ និងបង្កើនសុវត្ថិភាព។ ជាមួយនឹងការប្រើប្រាស់ប្រព័ន្ធដឹកជញ្ជូនឆ្លាត សិង្ហបុរីបានបង្កើតជាសេវាកម្មថ្មីៗសម្រាប់សម្រួលដល់ការធ្វើដំណើរ និងដឹកជញ្ជូនរបស់ប្រជាជន ដូចជា៖

➤ **គេហទំព័រ ONE.MONITORING៖** ជាគេហទំព័រដែលអាចឱ្យអ្នកបើកបរ និងម្ចាស់យានយន្តនៅសិង្ហបុរីអាចទទួលបានព័ត៌មានអំពីចរាចរណ៍ ដែលប្រមូលបានពីកាមេរ៉ាសុវត្ថិភាពដែលបំពាក់នៅតាមដងផ្លូវ និងប្រព័ន្ធ GPS ដែលបំពាក់នៅតាមតាក់ស៊ី។ អ្នកបើកបរអាចទទួលបានព័ត៌មានពីផ្លូវដែលគេកំពុងជួសជុល រូបភាពចរាចរណ៍ ការគណនាពេលវេលាធ្វើដំណើរ (Travel Time Calculator) ផែនទីផ្លូវ និងព័ត៌មានពីកន្លែងចតរថយន្ត។ វេបសាយនេះមិនត្រឹមតែផ្តល់ជូនព័ត៌មានអំពីចរាចរណ៍ប៉ុណ្ណោះទេ តែក៏មានផ្តល់ជូននូវព័ត៌មាន និងការណែនាំដល់ប្រជាពលរដ្ឋទាក់ទងនឹងការទិញ លក់ និងថែទាំយានយន្តរបស់ពួកគេទៀតផង។

➤ **ប្រព័ន្ធស្តារយានយន្ត (Vehicle Recover System)៖** អាជ្ញាធរប្រើកាមេរ៉ាសុវត្ថិភាពដើម្បីឃ្លាំមើលស្ថានការណ៍គ្រោះថ្នាក់ចរាចរណ៍។ នៅពេលមានគ្រោះថ្នាក់ចរាចរណ៍កើតឡើង អាជ្ញាធរមានសមត្ថកិច្ចអាចបញ្ជូនក្រុមការងារទទួលបន្ទុកទៅដល់កន្លែងកើតហេតុបានទាន់ពេលវេលា ដើម្បីអូស

យានយន្តដែលគ្រោះថ្នាក់ទៅដាក់ចំណតដែលនៅជិតបំផុត ដើម្បីបង្ការការកកស្ទះ។

- **សញ្ញាសម្គាល់ល្បឿនរបស់អ្នក (Your Speed Sign)៖** ជាឧបករណ៍អេឡិចត្រូនិកឆ្លាតមួយដែលអាចចាប់ល្បឿនយានយន្តជាក់ស្ដែង និងបង្ហាញដល់អ្នកបើកបរភ្លាមៗ ប្រសិនបើពួកគេបើកបរហួសល្បឿនកំណត់ ដើម្បីជួយបង្កើនសុវត្ថិភាពតាមដងផ្លូវ។



## ២. សេវាសុខាភិបាលឆ្លាត

រដ្ឋាភិបាលសិង្ហបុរីបានបង្កើតឱ្យមានប្រព័ន្ធថែទាំសុខភាពឌីជីថលក្នុងការឆ្លើយតបទៅនឹងការកើនឡើងនៃចំនួនប្រជាជនវ័យចំណាស់នៅក្នុងប្រទេស ដោយបង្កើតឱ្យមាននូវការពិគ្រោះយោបល់តាមអនឡាញជាមួយវេជ្ជបណ្ឌិត ព្រមទាំងបង្កើតឧបករណ៍ដែលអាចពាក់ជាប់ខ្លួនដើម្បីតាមដានស្ថានភាពរបស់អ្នកជំងឺ។



## ៣. សុវត្ថិភាព និងសន្តិសុខរបស់ប្រជាពលរដ្ឋ

យោងតាមរបាយការណ៍របស់CNBC សិង្ហបុរីជាប់ចំណាត់ថ្នាក់លេខ៣ ជាប្រទេសដែលមានសុវត្ថិភាពបំផុត។ កម្លាំងប៉ូលីសសិង្ហបុរីបានបង្កើត**មជ្ឈមណ្ឌលប៉ូលីសអេឡិចត្រូនិក** ដែលប្រជាជនអាចប្រើប្រាស់សេវាកម្មនានាបានតាមរយៈគេហទំព័រ sso.police.gov.sg។ សេវាកម្មទាំងនោះរួមមាន ការទទួលបានព័ត៌មាន ការដាក់ពាក្យបណ្ដឹងតាមអ៊ីនធឺណិត និងការផ្ដល់ជូនជាសេវាកម្មរដ្ឋបាលនានា ដូចជាការដាក់ពាក្យសុំច្បាប់ថតចម្លងរបាយការណ៍ប៉ូលីស និងកំណត់ត្រាឧក្រិដ្ឋកម្មជាដើម។




## ៤. ការសង្គ្រោះបន្ទាន់

▸ **កម្មវិធីទូរស័ព្ទ myResponders៖** កម្មវិធីទូរស័ព្ទ myResponders ត្រូវបានដាក់ឱ្យដំណើរការក្នុងខែមេសា ឆ្នាំ២០១៥។ កម្មវិធីទូរស័ព្ទដៃនេះនឹងជូនដំណឹងដល់អ្នកប្រើប្រាស់ក្នុងករណីសង្ស័យថាអាចមានការគាំងបេះដូង នៅពេលចង្វាក់បេះដូងអ្នកលោតខុសធម្មតា។

▸ **គេហទំព័រ scdf.gov.sg៖** នៅក្នុងគេហទំព័រ scdf.gov.sg ប្រជាជនអាចផ្ដល់ជាមតិយោបល់ ទទួលបានព័ត៌មានពីការប្រើប្រាស់ឧបករណ៍ពន្លត់អគ្គីភ័យ របៀបសង្គ្រោះបឋម ព្រមទាំងអាចចូលមើលរបាយការណ៍ប្រចាំឆ្នាំរបស់កងកម្លាំងការពារស៊ីវិលសិង្ហបុរី (Singapore Civil Defense Force) ដែលផ្ដល់ព័ត៌មានទាក់ទងនឹងអគ្គីភ័យ និងការសង្គ្រោះផ្នែកវេជ្ជសាស្ត្រ។



## ៥. បរិស្ថាន

គម្រោងកសាងទីក្រុងឆ្លាតរបស់សិង្ហបុរីក៏បានរួមបញ្ចូលការសន្សំសំចៃថាមពល និងការការពារបរិស្ថាន។ រដ្ឋាភិបាលសិង្ហបុរីបានប្រើប្រាស់បច្ចេកវិទ្យាថ្មីៗសម្រាប់ជួយដល់បរិស្ថាន ដូចជា៖

➤ **សែនស័រ៖** ការប្រើប្រាស់សែនស័របានជួយឱ្យអំពូលភ្លើងតាមផ្ទះ និងអគារអាចបិទ-បើក ដោយស្វ័យប្រវត្តិ ដែលជួយសន្សំសំចៃថាមពលបានច្រើន។

➤ **ធុងសំរាមឆ្លាត៖** នៅឆ្នាំ២០១៥ ធុងសំរាមឆ្លាតត្រូវបានដាក់ឱ្យប្រើប្រាស់ដើម្បីចូលរួមក្នុងការគ្រប់គ្រងសំណល់រឹងនៅប្រទេសសិង្ហបុរី។ សែនស័រដែលដាក់នៅតាមគម្របធុងសំរាមអាចជួយផ្តល់ព័ត៌មានពីកម្រិតបរិមាណសំរាម និងទីតាំងដល់អ្នកប្រមូល។ អ្នកប្រមូលសំរាមអាចដឹងពីពេលវេលា និងទីកន្លែងជាក់លាក់ ដែលចាំបាច់ត្រូវប្រមូលសំរាម ដែលការណ៍នេះបានជួយសន្សំសំចៃពេលវេលាធនធាន និងធ្វើឱ្យទីក្រុងស្អាតជានិច្ច។




## ៦. ការប្រាស្រ័យទាក់ទង

សិង្ហបុរីជាប្រទេសដែលឈានមុខគេក្នុងការអនុវត្តរដ្ឋាភិបាលអេឡិចត្រូនិក (e-Government)។ កម្មវិធីរដ្ឋាភិបាលអេឡិចត្រូនិកត្រូវបានបែងចែកជា ៣ប្រភេទ រួមមាន កម្មវិធីសម្រាប់ប្រជាពលរដ្ឋ កម្មវិធីសម្រាប់អាជីវកម្ម និងកម្មវិធីសម្រាប់រដ្ឋាភិបាល។ ខាងក្រោមនេះជាឧទាហរណ៍នៃកម្មវិធីប្រភេទនីមួយៗ៖

➤ **កម្មវិធីសម្រាប់ប្រជាពលរដ្ឋ៖** គេហទំព័រ data.gov.sg ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ២០១១ ដែលអាចឱ្យសាធារណៈជនទាញយកទិន្នន័យរដ្ឋាភិបាលបាន។ មិនតែប៉ុណ្ណោះ បច្ចេកវិទ្យា **SingPass** បានអនុញ្ញាតឱ្យប្រជាជនសិង្ហបុរីអាចទាក់ទងក្រសួង-ស្ថាប័នរបស់រដ្ឋាភិបាលជាង ៦០កន្លែង តាមរយៈប្រព័ន្ធអ៊ីនធឺណិតបានយ៉ាងងាយស្រួល និងមានសុវត្ថិភាព។ ម្យ៉ាងទៀត កម្មវិធី **Moments of Life** ក៏បានដាក់បញ្ចូលរាល់សេវាកម្មរបស់រដ្ឋាភិបាលទាំងអស់នៅលើកម្មវិធីតែមួយ។

› **កម្មវិធីសម្រាប់អាជីវកម្ម៖** រដ្ឋាភិបាលសិង្ហបុរីក៏បានបង្កើតសេវាកម្មលើកទឹកចិត្តដល់អាជីវកម្ម (Business Incentive Profiler) ដែលអនុញ្ញាតឱ្យអាជីករធ្វើការស្នើសុំជំនួយ តាមរយៈគេហទំព័ររបស់រដ្ឋាភិបាល។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលសិង្ហបុរីក៏បានបង្កើតថ្នាលឌីជីថលសម្រាប់ការផ្តល់អាជ្ញាបណ្ណអាជីវកម្មតាមប្រព័ន្ធអនឡាញ (Online Business Licensing Service) ដែលអនុញ្ញាតឱ្យអាជីវករធ្វើការស្នើសុំ ធ្វើបច្ចុប្បន្នភាព បន្ត និងបញ្ចប់អាជ្ញាបណ្ណអាជីវកម្មនានាតាមប្រព័ន្ធអនឡាញតែម្តង។

› **កម្មវិធីសម្រាប់រដ្ឋាភិបាល៖** កម្មវិធីសម្រាប់រដ្ឋាភិបាល រួមមាន G-Cloud អាចឱ្យស្ថាប័នរដ្ឋាភិបាលធ្វើការចែករំលែកទិន្នន័យរវាងគ្នាបានដោយងាយស្រួល ហើយកម្មវិធី Cube ក៏បានជួយឱ្យមន្ត្រីតាមស្ថាប័ននានា ធ្វើការទំនាក់ទំនង និងចែករំលែកគំនិតឱ្យគ្នាទៅវិញទៅមក។



## ៧. ការសិក្សាស្រាវជ្រាវ

គំនិតផ្តួចផ្តើមថ្នាក់ជាតិ "Smart Nation" របស់សិង្ហបុរី ប្រើប្រាស់ទិន្នន័យធំ និងបញ្ញាសិប្បនិម្មិតដើម្បីឱ្យអ្នកដឹកនាំអាចស្វែងយល់ពីដំណើរការរបស់ទីក្រុង កំណត់របៀប និងពេលវេលាទប់ស្កាត់បញ្ហាដែលអាចកើតមានឡើង ព្រមទាំងអនុញ្ញាតឱ្យអ្នកដឹកនាំស្រមៃពីទីក្រុងនៅថ្ងៃអនាគត។ រដ្ឋាភិបាលសិង្ហបុរីបានយកចិត្តទុកដាក់ខ្លាំងលើផ្នែកស្រាវជ្រាវ ដោយបានបង្កើតជា Lee Kuan Yew Center for Innovative Cities ដែលបង្កើតឡើងដើម្បីស្រាវជ្រាវលើបញ្ហាសំខាន់ៗនៃទីក្រុង និងនគរូបនីយកម្ម ព្រមទាំងស្វែងយល់ពីការប្រើប្រាស់បច្ចេកវិទ្យា និងគោលនយោបាយដើម្បីផ្តល់ដំណោះស្រាយចំពោះបញ្ហានានាក្នុងទីក្រុង។



## III. ករណីសិក្សា៖ ការកសាងទីក្រុងឆ្លាតនៅប្រទេសកម្ពុជា

នៅក្នុងក្របខណ្ឌនៃការកសាងទីក្រុងឆ្លាតនៅតំបន់អាស៊ាន កម្ពុជាបានកំណត់យកទីក្រុងធំៗ ចំនួន ៣ រួមមាន **រាជធានីភ្នំពេញ, ក្រុងសៀមរាប និងក្រុងបាត់ដំបង**។ ចក្ខុវិស័យក្នុងការអភិវឌ្ឍទីក្រុងឆ្លាតនៅរាជធានីភ្នំពេញ គឺផ្តោតលើការធ្វើឱ្យប្រសើរឡើងនូវបរិស្ថានទីក្រុង ដើម្បីលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋ ដែលទាមទារឱ្យមានការកសាងនូវហេដ្ឋារចនាសម្ព័ន្ធបៃតង សំដៅធានានិរន្តរភាពបរិស្ថាន និងកំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងអនាគត។ មិនតែប៉ុណ្ណោះ ការអភិវឌ្ឍទីក្រុងឆ្លាតនៅភ្នំពេញបានផ្តោតលើការរៀបចំកន្លែងសាធារណៈ ដែលអាចធានាបាននូវបរិស្ថានល្អ ព្រមទាំងបង្កើតឱកាសឱ្យពលរដ្ឋចូលរួមផ្តល់ជាមតិយោបល់តាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីនានាដែលអាចជាជំនួយក្នុងការកែលម្អកន្លែងសាធារណៈ និងការដឹកជញ្ជូនសាធារណៈឱ្យកាន់តែប្រសើរ។ ដោយឡែក សម្រាប់ទីក្រុងសៀមរាប គឺផ្តោតលើការកែប្រែក្រុងសៀមរាបឱ្យក្លាយជាគោលដៅទេសចរណ៍វៃឆ្លាត ដោយផ្អែកលើការចូលរួមពីប្រជាពលរដ្ឋ និងសង្គម។ ទីក្រុងទេសចរណ៍មួយនេះត្រូវបន្តយកចិត្តទុកដាក់លើការពង្រឹងសេវាកម្មសម្រាប់ភ្ញៀវទេសចរ និងការធានាសន្តិសុខ សុវត្ថិភាពដោយមានការបំពាក់នូវកាមេរ៉ាសុវត្ថិភាព និងសៃនស័រសម្រាប់គ្រប់គ្រងចរាចរណ៍។ មិនតែប៉ុណ្ណោះ ការសម្រេចបាននូវការអភិវឌ្ឍទីក្រុងឆ្លាតនៅសៀមរាបអាចធ្វើទៅបានក៏ទាមទារឱ្យមានការពង្រឹងគុណភាពបរិស្ថាន និងការគ្រប់គ្រងធនធានឱ្យបានល្អប្រសើរ ដូចជាការពង្រឹងការគ្រប់គ្រងសំណល់ និងការគ្រប់គ្រងគុណភាពទឹកជាដើម។ ចំពោះទីក្រុងបាត់ដំបងចក្ខុវិស័យក្នុងការអភិវឌ្ឍទីក្រុងឆ្លាតគឺផ្តោតលើការសម្រេចឱ្យបាននូវទីក្រុងមួយដែលមានការអភិវឌ្ឍប្រកបដោយការទទួលខុសត្រូវ បរិស្ថានស្អាត

និងសេដ្ឋកិច្ចល្អប្រសើរ ព្រមទាំងការរក្សាបាននូវលក្ខណៈពិសេសរបស់ខេត្តបាត់ដំបង។ គម្រោងកសាងទីក្រុងឆ្លាតនៅក្រុងបាត់ដំបងផ្តោតលើការពង្រឹងគុណភាពបរិស្ថាន តាមរយៈការគ្រប់គ្រងប្រព័ន្ធបង្ហូរសំណល់រាវ, ការលើកកម្ពស់ការយល់ដឹងជាសាធារណៈលើការគ្រប់គ្រងសំណល់ និងការធ្វើប្រព្រឹត្តកម្មសំណល់រាវ។

លើសពីនេះទៀត រាជរដ្ឋាភិបាលបាននឹងកំពុងជំរុញរៀបចំគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីដើម្បីអភិវឌ្ឍន៍**ខេត្តព្រះសីហនុ ជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង** ដែលក្នុងនោះមានផ្តោតលើការកសាងក្រុងព្រះសីហនុជាទីក្រុងឆ្លាតផងដែរ។ យោងតាមប្រភពក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានឱ្យនិយមន័យ "ទីក្រុងឆ្លាត" សម្រាប់ករណីកម្ពុជា ថាជាទីក្រុងដែលដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍន៍ ដោយប្រើប្រាស់ និងបំពាក់នូវបច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាផ្សេងទៀត ដើម្បីលើកកម្ពស់គុណភាពជីវិត បង្កើនការប្រកួតប្រជែង និងពង្រឹងប្រតិបត្តិការ ការផ្តល់សេវាកម្ម និងការអភិវឌ្ឍទីក្រុងឱ្យកាន់តែមានប្រសិទ្ធភាព ដែលអាចឆ្លើយតបទៅនឹងតម្រូវការនាពេលបច្ចុប្បន្ន និងអនាគត ប្រកបដោយចីរភាព និងបរិយាបន្ន។ ការកសាងទីក្រុងឆ្លាតបានផ្តោតលើវិស័យសំខាន់ៗដូចជា វិស័យសន្តិសុខ, សុវត្ថិភាព, ការរៀបចំដែនដីនគរូបនីយកម្ម, ហេដ្ឋារចនាសម្ព័ន្ធ, ប្រព័ន្ធចរាចរណ៍, ការដឹកជញ្ជូន, ទូរគមនាគមន៍, ឧស្សាហកម្ម, ពាណិជ្ជកម្ម, ប្រព័ន្ធរដ្ឋបាល, សេវាសាធារណៈ, សេវាសង្គម, លំនៅដ្ឋាន, ថាមពល, ការគ្រប់គ្រងសំណល់, ការគ្រប់គ្រងគ្រោះធម្មជាតិ, ឧក្រិដ្ឋកម្ម, បរិស្ថាន ព្រមទាំងវិស័យអាទិភាពផ្សេងទៀតនៅក្នុងទីក្រុង។

ជាមួយគ្នានេះផងដែរ **យុទ្ធសាស្រ្តចតុកោណ ដំណាក់កាលទី ៤** របស់រាជរដ្ឋាភិបាល បានចង្អុលបង្ហាញពីសារៈសំខាន់នៃការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន ដែលស្ថិតនៅក្នុងចតុកោណទី ៤ ដោយក្នុងនោះមុំទី ៣ នៃចតុកោណទី ៤នេះ ផ្តោតលើការពង្រឹងការគ្រប់គ្រងនគរូបនីយកម្ម ដែលជាមូលដ្ឋានគ្រឹះមួយសម្រាប់ការអភិវឌ្ឍទីក្រុងឆ្លាតនៅកម្ពុជា។ ក្រៅពីនេះ ភាពជាដៃគូ និងទំនាក់ទំនងជាមួយភាគីពាក់ព័ន្ធ ទាំងរដ្ឋ និងឯកជន ទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី ពិតជាមានសារៈសំខាន់ណាស់ ដើម្បីអាចឈានទៅសម្រេចបានការកសាងទីក្រុងឆ្លាត ក្នុងនោះរាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងសហការជាមួយប្រទេសកូរ៉េខាងត្បូង ចិន សិង្ហបុរី និងហុងកុង។

ខាងក្រោមនេះ ជាថ្នាលបច្ចេកវិទ្យាថ្មីៗមួយចំនួន ដែលរាជរដ្ឋាភិបាលបានដាក់ឱ្យប្រើប្រាស់សម្រាប់បំរើដល់ការធ្វើទំនើបកម្មសេវាសាធារណៈ ដែលជាជំហានមួយឆ្ពោះទៅរកការកសាងទីក្រុងឆ្លាត រួមមាន៖

**ទី១. ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន៖** កាលពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវ **«ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី២»** ដោយធុរជនអាចស្នើសុំអាជ្ញាបណ្ណ/វិញ្ញាបនបត្រ/លិខិតអនុញ្ញាត/ប្រកាសបង្កើត តាមអនឡាញ តាមរយៈគេហទំព័រ **www.registrationservices.gov.kh**។ ផតថលរួមនេះនឹងជួយសម្រួលដល់អាជីវករ និងវិនិយោគិន ក្នុងការចុះអាជ្ញាបណ្ណអាជីវកម្ម បង់ពន្ធ និងសាកសួរពី

ព័ត៌មាននានាទាក់ទងទៅនឹងការធ្វើអាជីវកម្មដែលផ្តល់ភាពងាយស្រួល និងចំណេញពេលវេលា។ លើសពីនេះទៀត ប្រតិបត្តិការស្វ័យប្រវត្តិនៃការទាញយកទិន្នន័យរបស់ក្រុមហ៊ុន/សហគ្រាស ជាសមិទ្ធផលនៃការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ តាមរយៈ **ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)**។ ការណ៍នេះមិនត្រឹមតែបង្កើនបទពិសោធន៍នៃការប្រើប្រាស់ឱ្យកាន់តែមានលក្ខណៈងាយស្រួលជាងមុន សម្រាប់ធុរជនក្នុងការបំពេញពាក្យស្នើសុំប៉ុណ្ណោះទេ ប៉ុន្តែក៏ជាបច្ច័យវិជ្ជមានដែលអនុញ្ញាតឱ្យក្រសួង-ស្ថាប័នអាចកាត់បន្ថយរយៈពេលត្រួតពិនិត្យពាក្យស្នើសុំ និងធានាបានថាទិន្នន័យរបស់ក្រុមហ៊ុន/សហគ្រាសនៅគ្រប់ក្រសួង-ស្ថាប័នមានសង្គតិភាពផងដែរ។

***ទី២. កម្មវិធីទូរស័ព្ទបាគង៖*** ធនាគារជាតិនៃកម្ពុជាប្រកាសដាក់ឱ្យដំណើរការ**ប្រព័ន្ធបាគង** ដែលជាប្រព័ន្ធទូទាត់សម័យថ្មីដំបូងនៅកម្ពុជា ដែលប្រព័ន្ធថ្មីនេះនឹងជួយឱ្យអ្នកប្រើប្រាស់សេវាធនាគារតាមរយៈប្រព័ន្ធទូរស័ព្ទ មានភាពងាយស្រួលក្នុងការទូទាត់ប្រាក់ឆ្លងពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុមួយទៅគ្រឹះស្ថានមួយទៀត ព្រមទាំងពង្រឹងសុវត្ថិភាពប្រព័ន្ធទូទាត់សងប្រាក់ ជំរុញបរិយាបន្នហិរញ្ញវត្ថុ និងជំរុញការទូទាត់ជាប្រាក់រៀលផងដែរ។

***ទី៣. កម្មវិធីទូរស័ព្ទ "ថែទាំផ្លូវ" (Road Care)៖*** ក្រសួងសាធារណការ និងដឹកជញ្ជូន បានបង្កើតកម្មវិធីទូរស័ព្ទ ***"ថែទាំផ្លូវ"*** ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋរាយការណ៍អំពីបញ្ហាផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដែលមានការខូចខាត ដើម្បីឱ្យក្រុមការងារទទួលបន្ទុកចុះជួសជុលបានទាន់ពេលវេលា សំដៅបង្ការគ្រោះថ្នាក់ផ្សេងៗ។

***ទី៤. កម្មវិធីស្វ័យសិក្សា (MoEYS E-Learning)៖*** ក្នុងបរិការណ៍នៃការរីករាលដាលនៃជំងឺកូវីដ-១៩ ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយ***សហភាពសហព័ន្ធយុវជនកម្ពុជា*** ដើម្បីដាក់ឱ្យដំណើរការកម្មវិធីទូរស័ព្ទ ដែលមានឈ្មោះថា ***"កម្មវិធីស្វ័យសិក្សា"*** កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ កន្លងទៅ។ សិស្សានុសិស្សនៅកម្រិតចំណេះទូទៅអាចធ្វើស្វ័យសិក្សាបន្ថែម ហើយលោកគ្រូ អ្នកគ្រូ ក៏ដូចជាអ្នកអាណាព្យាបាលអាចប្រើប្រាស់កម្មវិធីទូរស័ព្ទនេះជាជំនួយក្នុងការបង្រៀនកូន និងសិស្សានុសិស្ស និងជំរុញឱ្យមានការសិក្សាបំពេញបន្ថែម រំលឹកមេរៀន ឬរៀនត្រៀមសម្រាប់មេរៀនណាមួយដែលចាំបាច់ នៅគ្រប់កម្រិត និងគ្រប់ភូមិសិក្សានៃការអប់រំចំណេះទូទៅ។

***ទី៥. បណ្តាញ CCTV៖*** កាមេរ៉ាឃ្លាំមើលជាច្រើនត្រូវបានតំឡើងនៅតាមភ្លើងស្តុបក្នុងរាជធានីភ្នំពេញ ដើម្បីត្រួតពិនិត្យចរាចរណ៍ ក៏ដូចជាបង្កើនសន្តិសុខនៅក្នុងទីក្រុង។




## IV. សន្និដ្ឋាន

ជារួម ការអភិវឌ្ឍទីក្រុងឆ្លាតគឺជានិន្នាការសកល ស្របតាមការរីកចម្រើននៃបច្ចេកវិទ្យា ជាមួយនឹងកំណើនប្រជាសាស្ត្រ និងកំណើនឥតឈប់ឈរនៃតម្រូវការ។ បណ្តាប្រទេសនានានៅក្នុងតំបន់អាស៊ាន ក៏ដូចជាកម្ពុជា បានចាប់ផ្តើមគិតគូរពីការកសាងទីក្រុងឆ្លាត និងបានបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខណ្ឌទ្វេភាគី និងពហុភាគី សំដៅធានាដល់ការអភិវឌ្ឍទីក្រុង ដែលជាមូលដ្ឋានដ៏សំខាន់បំផុតមួយសម្រាប់កំណើន វិបុលភាព និងវឌ្ឍនភាពសេដ្ឋកិច្ច-សង្គម៕

# ឯកសារយោង


- *Making Sense: Leveraging the Science of Cities, World Cities Submit Webinar*, ចូលរួមកាលពីថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០២១,
- *Everything You Wanted to Know About Smart Cities*, ចូលអានថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១, https://www.researchgate.net/publication/306046857_Everything_You_Wanted_to_Know_About_Smart_Cities
- *68% of the world population projected to live in urban areas by 2050*, ចូលអានថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១, https://www.researchgate.net/publication/306046857_Everything_You_Wanted_to_Know_About_Smart_Cities
- *What Makes a City Smart?*, ចូលអានថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០២១, http://www.creaidealab.com/blog/what-makes-a-city-smart
- *Technology and Governance in Singapore's Smart Nation Initiative*, ចូលអានថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១, https://ashharvard.edu/files/ash/files/282181_hvd_ash_paper_jj_woo.pdf
- *This European capital has overtaken Tokyo and Singapore as the world's safest city*, ចូលអានថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២១, https://www.cnbc.com/2021/08/24/eiu-safe-cities-copenhagen-toronto-singapore-worlds-safest-cities.html
- *Phnom Penh Smart City Action Plan*, ចូលអានថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០២១, https://asean.org/wp-content/uploads/2019/02/Phnom-Penh.pdf
- *Siem Reap Smart City Action Plan*, ចូលអានថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២១, https://asean.org/wp-content/uploads/2019/02/Siem-Reap.pdf
- *Battambang Smart City Action Plan*, ចូលអានថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២១, https://asean.org/wp-content/uploads/2019/02/Battambang.pdf
- *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ របស់រាជរដ្ឋាភិបាល នីតិកាលទី ៦ នៃរដ្ឋសភា*, ចូលអានថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១, http://iric.gov.kh/wp-content/uploads/2018/09/Rectangular-Strategy-Phase-IV_KH-Version-.pdf
- *International Case Studies of Smart Cities*, ចូលអានថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២១, https://publications.iadb.org/publications/english/document/International-Case-Studies-of-Smart-Cities-Singapore-Republic-of-Singapore.pdf
- *ASEAN Smart Cities Framework*, ចូលអានថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១, https://asean.org/wp-content/uploads/2021/09/ASEAN-Smart-Cities-Framework.pdf
- *Cambodia prepares the ground for smart cities*, ចូលអានថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២១, https://www.khmertimeskh.com/507279/cambodia-prepares-the-ground-for-smart-cities/

- *ការអភិវឌ្ឍទីក្រុងឆ្លាតនៅកម្ពុជា៖ គោលនយោបាយ និងផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល,កម្មវិធី ជជែកពីកម្ពុជា ៤.0, វាគ្មិនកិត្តិយស លោក សេក សុធីរិទ្ធ ប្រធាននាយកដ្ឋាននគរូបនីយកម្ម នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ផ្សាយផ្ទាល់កាលពីថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០២១*
- *ASEAN´s rapid urbanization faces sustainability woes, ចូលអានថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១, https://news.cgtn.com/news/7849544d33677a6333566d54/share_p.html*
- *សេចក្តីប្រកាសព័ត៌មានស្តីពី កម្មវិធីស្វ័យសិក្សា "MoEYS E-learning", ចូលអានថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២១ http://www.uyfc.org/news/moeys-e-learning-2/*
- *សេចក្តីប្រកាសព័ត៌មានស្តីពីការដាក់ឱ្យដំណើរការជាផ្លូវការនូវ «ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី២», ចូលអានថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១,https://www.registrationservices.gov.kh/wp-content/uploads/2021/08/Press-Release-for-OBR-Phase-II-Khmer-and-English.pdf*

---


www.cambodia4point0.org

កម្ពុជា ៤.0 - Cambodia 4.0

cambodia_4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center

Cambodia 4.0